# អង្គការសង្គមស៊ីវិលយល់ឃើញថាដីរដ្ឋគួរដកហូតមកវិញក្រោយកម្ទេចរបងនៅឆ្នេរអូរឈើទាល ។



ទីតាំងរបងដែលសង់លើឆ្នេរអូរឈើទាល ត្រូវបានអាជ្ញាធរខេត្តវាយកម្ទេចចោលជាស្ថាពរហើយកាលពីយប់ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រោយរងការរិះគន់ និងមានការផ្សព្វផ្សាយពីបណ្ដាញសារព័ត៌មាន។ (ផ្ដល់ឱ្យ)

ក្រុមអង្គការសង្គមស៊ីវិល អំពាវនាវឱ្យរដ្ឋាភិបាលត្រូវនិរាករចោលនូវប្លង់កម្មសិទ្ធិដែលទទួលបានភាពស្របច្បាប់ ក្នុងនាមជានីតិបុគ្គល ទៅលើផ្ទៃដីមួយប្លង់ដែលមានទំហំជាង **៨ពាន់ម៉ែត្រការ៉េ** ដែលគេចាត់ទុកថា ការអនុវត្តបែបនេះ វាជាការបំពានទៅនឹងគោលការណ៍ច្បាប់ ហើយធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាពតំបន់ឆ្នេរសមុទ្រថែមទៀតផង។

ប្រតិកម្មពីអ្នកជំនាញការស្រាវជ្រាវការអភិវឌ្ឍសង្គម និងអង្គការមិនមែនរដ្ឋាភិបាលនេះ ស្របពេលរដ្ឋបាលខេត្តព្រះសីហនុ បានបញ្ជាក់នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី៩

ខែកុម្ភៈ ហើយថា របងដែលនៅលើដីតំបន់ឆ្នេរសមុទ្រនេះ ត្រូវបានកម្ទេចចោលជាស្ថាពរហើយ គិតត្រឹមយប់ថ្ងៃទី៨ ខែកុម្ភៈនេះ។

លោក **វណ្ណ សុផាត** អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា យល់ឃើញថា ផ្អែកគោលការណ៍ច្បាប់ ដីតំបន់ឆ្នេរសមុទ្រនេះមិនគួរមានការកាន់កាប់ដោយឯកជនណាមួយទេ។ លោកបន្តថា បើទោះជានៅពេលនេះ រដ្ឋបាលខេត្តព្រះសីហនុ ចុះអនុវត្តដោយតម្រូវឱ្យមានការវាយកម្ទេចរបងថ្មដែលរំលោភចូលឆ្នេរសមុទ្រក្ដី ភាពចាំបាច់បន្ត គឺត្រូវដកហូតដីនេះមកជាសម្បត្តិរដ្ឋវិញ។

លោកបន្តថា៖ «អាហ្នឹងត្រូវជាសម្បត្តិរបស់រដ្ឋ សម្រាប់ប្រយោជន៍សាធារណៈ។អាហ្នឹងមិនត្រូវតែជាសំណាង់រឹងរបស់បុគ្គលណា ឬក៏ជារបស់ក្រុមហ៊ុនណាទេ វាត្រូវតែជាទ្រព្យសម្បត្តិសម្រាប់ផលប្រយោជន៍សាធារណៈ ហើយសាធារណជនអាចទៅលេងកម្សាន្តនៅតំបន់ឆ្នេររបស់យើងបាន»។

មិនមែនមានតែអ្នកជំនាញផ្នែកធុរកិច្ចនេះទេ អ្នកវិភាគសង្គម និងនយោបាយ ក៏បង្ហាញប្រតិកម្មរបស់ពួកគេនៅលើបណ្ដាញសង្គមដែរ ក្រោយយុទ្ធនាការវាយកម្ទេចរបងថ្មកើតឡើងដោយអាជ្ញាធរខេត្តព្រះសីហនុ នៅពេលនេះ។



*ទីតាំងរបងដែលសង់លើផ្ទៃរអូរឈើទាល ត្រូវបានអាជ្ញាធរខេត្តវាយកម្ទេចចោលជាស្ថាពរហើយកាលពីយប់ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រោយរងការរិះគន់ និងមានការផ្សព្វផ្សាយពីបណ្ដាញសារព័ត៌មាន។ (ផ្ដល់ឱ្យ)*

លោកបណ្ឌិត **ឡៅ ម៉ុងហៃ** អ្នកវិភាគសង្គម និងនយោបាយចាស់វស្សាម្នាក់រូប បាន លើកឡើងតាមរយៈសំណេររបស់លោកនៅលើបណ្ដាញសង្គមហ្វេសប៊ុក តបនឹង ការបញ្ចេញមតិរបស់លោកបណ្ឌិត **មាស នី** ថាអ្នកដែលបំពានគោលការណ៍ច្បាប់ គួរត្រូវបានអនុវត្តទៅតាមនីតិវិធី និងមិនគួរលើកលែងក្នុងហេតុផលណាមួយឡើយ។

លោកបន្តថា៖ «**អ្នករំលោភច្បាប់ ត្រូវទទួលទណ្ឌកម្ម មិនត្រូវឱ្យរួចខ្លួនទេ**»។

មិនខុសគ្នាទេ លោកបណ្ឌិត **មាស នី** អ្នកស្រាវជ្រាវការអភិវឌ្ឍសង្គម ក៏ឯកភាពដែរ ថា ច្បាប់ដែលមានស្រាប់ហើយ ដូចជា ច្បាប់ភូមិបាល ជាដើម វាគួរយកមកអនុវត្ត ចំពោះអ្នកប្រព្រឹត្តបទល្មើស។ តាមរយៈសំណេររបស់ខ្លួននៅលើបណ្ដាញសង្គមហ្វេ

សប៊ុកនៅថ្ងៃនេះ លោកបណ្ឌិត មាស នី លើកឡើងថា ការអនុវត្តច្បាប់នៅពេលនេះ របស់មន្ត្រីនៅថ្នាក់ក្រោមជាតិ ចំពោះការសាងសង់របងថ្មនេះ វាគួរទប់ស្កាត់តាំងពីក្នុងដំណាក់កាលនៃការសាងសង់ដំបូងទីមក។ លោកបន្តថា ការបណ្ដែតបណ្ដោយហូតរបងស្ទើរក្លាយទៅគ្រឹះបែបនេះ ឆ្លុះបញ្ចាំងឱ្យឃើញថា មន្ត្រីនៅថ្នាក់ក្រោមហាក់មិនចេះធ្វើការ។

លោកបន្តថា៖ «**ទើសត្រចៀកពេក សុំលូកមាត់បន្តិចសម្រាប់របងថ្មនៅអូរឈើទាល ទើបវាយកម្ទេច! ច្បាប់ភូមិបាលបាននិយាយច្បាស់ពីចំណីដីសមុទ្រ។ ដូច្នេះការសាងសង់របងក៏មិនមែនលួចធ្វើមួយម៉ោងហើយដែរ អាចប្រើពេលច្រើនអាទិត្យ ចុះហេតុអ្វីបានជាអាជ្ញាធរមូលដ្ឋានមិនដឹង ទុករហូតដល់មហាជនស្រែក ហើយថ្នាក់ដឹកនាំចេញបញ្ជា ទើបចេញវិធានការ**»។

ឆ្លើយតបរឿងនេះ អភិបាលរងខេត្ត និងជាអ្នកនាំពាក្យសាលាខេត្តព្រះសីហនុ លោក **ឡុង ឌីម៉ង់** បញ្ជាក់នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣នេះថា អាជ្ញាធរខេត្តបានទទួលគោលការណ៍ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យសម្របសម្រួលជាមួយម្ចាស់កម្មសិទ្ធិដីនៅតំបន់ឆ្នេរអូរឈើទាល ហើយក៏ឈានទៅដល់ការកម្ទេចរបងដែលហ៊ុមព័ន្ធតំបន់ឆ្នេរ កាលពីយប់ថ្ងៃទី៨ ខែកុម្ភៈនេះ អស់ហើយ។

បើតាមលោក **ឡុង ឌីម៉ង់** នៅចំពោះមុខនេះ អាជ្ញាធរថ្នាក់ខេត្ត បានត្រឹមអនុវត្តគោលការណ៍នៅឡើយប៉ុណ្ណោះ នៅត្រង់ថាតើនឹងត្រូវដកហូតដីនៅតំបន់ឆ្នេរ មកឱ្យរដ្ឋគ្រប់គ្រងវិញ ឬត្រូវបន្តបែបណានោះ គឺត្រូវរង់ចាំបន្តទៅមុខទៀតសិន។

លោកបន្តថា៖ «**ដូចខ្ញុំបានជម្រាបខាងដើមអ៊ីចឹង ថាគោលការណ៍ណែនាំដែលយើងបានមក គឺយើងបានត្រឹមសម្របសម្រួលជាមួយម្ចាស់ ក្នុងការវាយរបងប៉ែកខាងសមុទ្រចេញ។ យើងអត់មានការណែនាំថាត្រូវដកមកវិញដកអី យើងមិនមែនជាអ្នកដក**

ទេ។ ដូចខ្ញុំតែងតែបញ្ជាក់អ៊ីចឹង ថាដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តមិនមានសិទ្ធិក្នុងការដកហូតដីដែលមានបណ្ណកម្មសិទ្ធិបានទេ។ អ្នកដកហូតបាន មានតែរាជរដ្ឋាភិបាល មានតែសាលក្រមតុលាការអីអ៊ីចឹងទៅណា»។

បើគេពិនិត្យដោយផ្ទាល់ឃើញថា របងដែលរៀបចំស្ទើរដូចជាមហាកំផែងមួយទៅហើយនេះ មានគម្លាតពីទឹកសមុទ្រប្រមាណ ១២ម៉ែត្រ នៅពេលទឹកនាច ហើយនៅពេលទឹកជោរវិញ ចម្ងាយពីរបងទៅទឹកសមុទ្រចន្លោះប្រហែលពី ៤ ទៅ ៥ម៉ែត្រប៉ុណ្ណោះ។ ទីតាំងនេះស្ថិតនៅឆៀងខាងត្បូង នៃម្ខាងផ្លូវថ្នល់ និងនៅមិនឆ្ងាយប៉ុន្មានពីផ្ទះលំហែរបស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។

បើគិតពីគម្លាតនៃតំបន់ឆ្នេរ មកទីតាំងនៃការសាង់សងរបងនេះ គឺហាក់ដើរហួសពីបន្ទាត់នៃគោលការណ៍ច្បាប់។

រដ្ឋាភិបាលបានចេញសេចក្ដីជូនដំណឹងលេខ ០១ កាលពីដើមខែកុម្ភៈ ឆ្នាំ២០១២ ដោយកំណត់ថា ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត នៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ ឬសាងសង់ជាថ្ម ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។

ការកំណត់ថាជាទំហំឆ្នេរសមុទ្រ គឺរាប់សម្រាប់ឆ្នេរជម្រាល ត្រូវកំណត់យ៉ាងតិច ៣០ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត ទៅដល់ដីគោក។ ចំណែកឆ្នេរចោទវិញ ត្រូវកំណត់យ៉ាងតិច ២០ម៉ែត្រ ចាប់ពីចំណុចកណ្ដាលនៃផ្ទៃចោទមកដីគោក។ នៅក្នុងបញ្ញត្តិស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនេះដែរ ដីឆ្នេរសមុទ្រគឺហាមសាងសង់សំណង់រឹង លើកលែងតែការសាងសង់នោះបម្រើឱ្យសេចក្ដីត្រូវការសម្រាប់ប្រយោជន៍សាធារណៈ។

បើទោះបែបណា របងដែលធ្វើរំលោភចូលដីតំបន់ឆ្នេរនេះ ត្រូវបានកម្ទេចចោលហើយ កាលពីយប់ថ្ងៃទី៨ ខែកុម្ភៈ ប៉ុន្តែការវាយកម្ទេចនេះ អនុវត្តតែចំពោះជ្រុងម្ខាងដែលលយចូលក្នុងសមុទ្រប៉ុណ្ណោះ។ ដោយឡែក ជ្រុងទាំងសងខាងនៃរបង និងរបងដែលហ៊ុមព័ទ្ធពីខាងមុខផ្ទះនៃខ្លោងទ្វារចូល គឺនៅរក្សាសភាពធម្មតាដដែលនៅឡើយ។

ចំណែកពលរដ្ឋដែលរស់នៅក្នុងខេត្តព្រះសីហនុ ថ្លែងក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះ លើកឡើងថា ការបង្ហាញពីឆន្ទៈនេះហាក់មិនទាន់អាចជឿទុកចិត្តបាននៅឡើយទេ ថាតើរដ្ឋាភិបាលធ្វើនេះពិតជាមានភាពស្មោះត្រង់មែន ឬយ៉ាងណា។ ប្រភពបន្តថា នេះមិនមែនជាលើកទី១ទេ ដែលអាជ្ញាធរតែងធ្វើបែបនេះ កន្លងទៅ ក៏ធ្លាប់មានតំបន់ឆ្នេរច្រើនណាស់ដែរ ដែលមានបញ្ហាហើយទប់ស្កាត់ តែក្រោយមកបានបន្តលួចសាងសង់ឡើងវិញជាធម្មតា។

ប្រភពដដែលបន្តថា ម្យ៉ាងវិញទៀត រដូវកាលនេះកាន់តែកៀកបោះឆ្នោតផង ដូច្នេះចង់ឬមិនចង់ ដើម្បីរំងាប់ចិត្តពលរដ្ឋ រដ្ឋាភិបាលត្រូវបង្ខំចិត្តធ្វើបែបនេះមួយគ្រាសិនក៏អាចថាបាន។ ចំណុចសំខាន់ ប្រសិនបើប្លង់កម្មសិទ្ធិនៅតែមិនត្រូវបាននិរាករទេ នោះមានន័យថា ទីតាំងនេះងាយនឹងសាងសង់ឡើងវិញនៅពេលណាមួយ។

លោកបន្តថា៖ «ចំពោះការវាយរបងនៅឆ្នេរអូរឈើទាលហ្នឹង ខ្ញុំចូលរួមត្រេកអរ ប៉ុន្តែខ្ញុំមិនទាន់ជឿជាក់ទាំងស្រុងទេ ដរាបណាគេមិនទាន់និរាករប្លង់ដីនោះចោល។ មូលហេតុដែលខ្ញុំមិនទាន់ជឿជាក់ទាំងស្រុង សម្ដេចនាយករដ្ឋមន្ត្រី លោកធ្លាប់បញ្ជាឱ្យឯកឧត្តម ជា សុផារ៉ា កាយដីឆ្នេរនៅឆ្នេរព្រែកត្រែងម្ដងដែរ កាលណោះខ្ញុំសង្កេតឃើញថា គេកាយបានតែប៉ុន្មានឡានទេ តែជាក់ស្ដែងដីក្រហមដែលចាក់ចូលឆ្នេរហ្នឹងគឺនៅដដែល គឺវាមិនកាយ និងជីកបានទាំងស្រុងទេ។ រីឯឆ្នេរឯករាជ្យវិញ ក្នុងពេលកន្លងទៅ ត្រូវបានព័ទ្ធរបងធ្វើជាកម្មសិទ្ធិឯកជនដែរ ប៉ុន្តែពេលនោះត្រូវបានអតី

តអភិបាលខេត្ត លោក យន្ត មីន គាត់បញ្ជាឱ្យកម្ទេចចោល ប៉ុន្តែមួយរយៈក្រោយមក សំណង់រឹងនៅលើឆ្នេរឯករាជ្យនោះក៏ត្រូវបានសាងសង់ឡើងវិញ»។

មកដល់ពេលនេះ ទីតាំងដីដែលជាអតីតវរនគរបាលជើងទឹក ដែលត្រូវបានគេហ៊ុមព័ទ្ធរបងធ្វើជាកម្មសិទ្ធិ នៅតំបន់ឆ្នេរអូរឈើទាល នៅតែជាអាថ៌កំបាំង មិនដឹងថាតើអ្នកណាជាម្ចាស់ឱ្យពិតប្រាកដនៅឡើយ៕